**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិដឹកនាំអនុវត្តកម្មវិធីផ្តល់ដី**
**ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព(ផ.ក.អ.)**
**លេខាធិការដ្ឋាន**

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីដំណើរការអនុវត្តកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព

លេខាធិការដ្ឋានគណៈកម្មាការធិការជាតិដឹកនាំអនុវត្តកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព មានកិត្តិយសជម្រាបជូនសាធារណជនមេត្តាជ្រាបថា÷ រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បាននិងកំពុងដាក់ឱ្យដំណើរការ "**កម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព**" ក្នុងគោលបំណងបង្កើនការការពារ និងអភិរក្សធនធានធម្មជាតិប្រកបដោយចីរភាពសម្រាប់កូនចៅតជំនាន់ផង និងបង្កើនប្រសិទ្ធភាព ផលិតភាពនៃការប្រើប្រាស់ដីរដ្ឋផង តាមរយៈការផ្តល់ដីក្រោមទម្រង់សម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រគ្មានដីសម្រាប់សង់លំនៅឋាននិងក្រីក្រគ្មានដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ និងគាំទ្រគម្រោងអភិវឌ្ឍសហគមន៍ ព្រមទាំងការពារព្រៃនៅជិតទីតាំងផ្តល់ដីប្រកបដោយចីរភាព។ កម្មវិធីនេះផ្តួចផ្តើមដោយ**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី**ដែលនឹងផ្តល់ដីនៅក្នុងតំបន់មួយចំនួនដល់អ្នកក្រីក្រគ្មានដីពិតប្រាកដ ប្រកបដោយសមធម៌ដើម្បីរួមគ្នាកសាងសហគមន៍ក្នុងការប្រើប្រាស់ អាស្រ័យផល និងការការពារព្រៃនិងដីរដ្ឋសម្រាប់ការអភិវឌ្ឍដោយចីរភាព។

**កម្មវិធីនេះ រួមគ្នាគិត រួមគ្នាធ្វើ រួមគ្នាទទួលខុសត្រូវ និងរួមគ្នាទទួលផល ព្រមទាំងដោះស្រាយការទន្ទ្រានដីរដ្ឋ** ដែលដំណើរការអនុវត្តកម្មវិធីនេះ មានដំណាក់កាលសំខាន់ចំនួន៥ ដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម÷

១. **ដំណាក់កាលរៀបចំ** គ្របដណ្តប់លើយន្តការការកំណត់ទីតាំងដីនៅចំណុចអូរសែរ ភូមិហាងសាវ៉ាត ឃុំសាមឃួយ ស្រុកសេសាន្ត ខេត្តស្ទឹងត្រែង ហើយបានសិក្សាលក្ខណៈបច្ចេកទេសបម្រើឱ្យកម្មវិធីរួចរាល់ ដោយជំហានទី១ គ្រោងនឹងអនុវត្តចំនួន៥០០គ្រួសារ។ ដោយទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពី**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** និងជា**ប្រធាន ផ.ក.អ.** លេខាធិកាដ្ឋាន ផ.ក.អ. បានរៀបចំកញ្ចប់ផ្សព្វផ្សាយនិងបានបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធចំនួន២៥រាជធានី ខេត្តរួចរាល់ ចាប់ពីថ្ងៃទី១៥ ខែមករា ដល់ថ្ងៃទី២១ ខែមករា ឆ្នាំ២០២៥ មានអ្នកចូលរួម ៣ ២៧២នាក់ ដោយផ្តល់ព័ត៌មានពីកម្មវិធី ការធ្វើលិខិតស្នើយប្រកាស ការដាក់និងទទួលពាក្យ លក្ខណៈសម្បត្តិនិងកាតព្វកិច្ច អ្នកស្នើសុំដី ក្រុមការងារចំពោះកិច្ច ក្នុងការឆ្លុះបញ្ចាំងអ្នកស្នើសុំដី និងរបៀបរបបការងាររដ្ឋបាលថ្នាក់ក្រោមជាតិ។

២. **ដំណាក់កាលបច្ចេកទេស** ផ្តោតលើកិច្ចការរៀបចំដីធ្លីនិងរើសបុគ្គលមានសិទ្ធិទទួលដី។ ចំពោះការងារដីធ្លី ផ្តោតលើការចុះបញ្ជីដីរដ្ឋ ការរៀបចំផែនការប្រើប្រាស់ដី ការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការបែងចែកដីឡូតិ៍លម្អិត ការឈូសឆាយទីតាំង បោះបង្គោលព្រំទីតាំង និងដីឡូតិ៍។ ចំណែកឯការរើសបុគ្គលមានសិទ្ធិទទួលដី ដោយផ្សព្វផ្សាយជូនដំណឹងរយៈពេល៣០ថ្ងៃនិងដាក់ពាក្យរយៈពេល២០ថ្ងៃ នៅសាលាឃុំ/សង្កាត់ដែលសាមីខ្លួនរស់នៅអចិន្ត្រៃយ៍(ចាប់ទទួលពាក្យចាប់តាំងពីថ្ងៃផ្សព្វផ្សាយគឺថ្ងៃទី១ ខែកុម្ភៈ ដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៥)។ សាមីជនត្រូវធ្វើលិខិតស្នើយប្រកាសដាក់ពាក្យ ហើយរដ្ឋបាលឃុំ/សង្កាត់បញ្ជាក់ទទួលស្គាល់។ រដ្ឋបាល

ឃុំ/សង្កាត់ រៀបចំក្រុមការងារចំពោះកិច្ច ដើម្បីរៀបចំលក្ខណៈវិនិច្ឆ័យនិងមូលដ្ឋានពិន្ទុ ដើម្បីផ្ទៀងផ្ទាត់ភាពសមស្របក្នុងការជ្រើសរើសបុគ្គលមានសិទ្ធិទទួលដី។

៣. **ដំណាក់កាលពិនិត្យភាពសមស្រប(រយៈពេល៧២ថ្ងៃ)** ក្រុមការងារចំពោះកិច្ចផ្ទៀងផ្ទាត់ភាពសមស្របផ្អែកលើលក្ខណៈវិនិច្ឆ័យនិងតារាងពិន្ទុដែលបានរួមគ្នារៀបចំរួច រៀបបញ្ជីតាមលំដាប់អាទិភាពនៃកម្រិតក្រីក្រ កំណត់ហេតុនិងរបាយការណ៍ រួចបញ្ជូនឯកសារទាំងនោះតាមរយៈ ក្រុង/ស្រុក/ខណ្ឌ រាជធានី/ខេត្ត មកលេខាធិការដ្ឋានបូកសរុបរៀបចំកំណត់ហេតុនិងរបាយការណ៍លើបញ្ជីឈ្មោះបុគ្គលមានសិទ្ធិទទួលដី គោរពជូនគណៈកម្មាធិការជាតិពិនិត្យនិងសម្រេច។

៤. **ដំណាក់កាលពិនិត្យ សម្រេច និងផ្តល់សុពលភាព**លើ (១)បុគ្គលមានសិទ្ធិទទួលដីនិងបុគ្គលអាចមានសិទ្ធិទទួលដីបន្ទាប់ (២)ផែនការប្រើប្រាស់ដី (៣)ផែនការហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង (៤)ផែនការបែងចែកដីឡូតិ៍លម្អិតដោយគណៈកម្មាធិការជាតិ។

៥. **ដំណាក់កាលផ្តល់ដី ការពារព្រៃ និងការអភិវឌ្ឍន៍** ក្រោយមានការសម្រេចរបស់គណៈកម្មាធិការជាតិរួច លេខាធិការដ្ឋាន ជូនដំណឹងដល់បុគ្គលមានសិទ្ធិទទួលដីដើម្បីមកចាប់ឆ្នោតយកដី ហើយចុះកិច្ចសន្យា ព្រមទាំងបញ្ចូលព័ត៌មានទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យឌីជីថល។ រៀបចំពិធីប្រគល់ដីឡូតិ៍ និងផ្តល់បណ្ណសិទ្ធិកាន់កាប់ប្រើប្រាស់ដីនៃកម្មវិធី។ ចំណែកឯការចូលតាំងទីលំនៅ ដោយរៀបចំបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ហើយរៀបចំអភិវឌ្ឍសហគមន៍ឱ្យមាននិរន្តរភាព ដោយ(១)មានយន្តការគ្រប់គ្រង ថែទាំ គាំពារ តម្រង់ទិសជាប្រចាំ (២)លើកកម្ពស់សុខភាពអនាម័យ ហូបស្អាត ផឹកស្អាត ហាត់ប្រាណ សម្រាក សម្រាន្តទៀងទាត់ គ្រប់គ្រាន់ (៣)លើកកម្ពស់សមត្ថភាពគំនិតដោយបណ្តុះបណ្តាល និងប្រតិបត្តិ ផ្លាស់ប្តូរផ្នត់គំនិតពីអវិជ្ជមានទៅវិជ្ជមាន មិនខ្ជិល មិនខ្ជីខ្ជា មិនខ្ជះខ្ជាយ សន្សំសំចៃ ឧស្សាហ៍ព្យាយាម ជឿជាក់លើខ្លួនឯង ចេះជួយ ខ្លួនឯង និងជួយ អ្នកដទៃ មានគំនិតសហគមន៍ មានភាពជាអ្នកដឹកនាំ ជាអ្នកគ្រប់គ្រង ជាធុរជន ... (៤)លើកកម្ពស់កម្រិតជីវភាពតាមរយៈការបង្កើននូវសមត្ថភាពជំនាញតាមស្ថានភាពតម្រូវ លើកកម្ពស់ការបង្កបង្កើនផល ចូលរួមជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចក្នុងភាពជាដៃគូរជាមួយវិស័យឯកជនដោយពឹងកម្លាំងគ្នា ចែករំលែកទីផ្សារ បច្ចេកវិទ្យា ចំណេះដឹង ចំណេះធ្វើ ដោយគោរពគ្នាទៅវិញទៅមកនិងទទួលផលប្រយោជន៍ពីការការពារនិងដាំព្រៃឡើងវិញ។

លេខាធិការដ្ឋានសង្ឃឹមយ៉ាងមុតមាំថា សាធារណជននិងអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមចំណែក គាំទ្រនិងអនុវត្តយ៉ាងសកម្មក្នុងកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព ដោយស្មារតីទទួលខុសត្រូវខ្ពស់មនសិការស្នេហាជាតិ ក្នុងឧត្តមប្រយោជន៍ បម្រើប្រជាពលរដ្ឋនិងប្រទេសជាតិ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកលេខាធិការដ្ឋានតាមរយៈទូរស័ព្ទ Hotline 1255 (ដោយឥតគិតថ្លៃ) នៅរៀងរាល់ម៉ោងធ្វើការ ឆានែលតេឡេក្រាម÷ https://bit.ly/secpka និងផេកហ្វេសប៊ុកផ្លូវការ÷ លេខាធិការដ្ឋាន ផ.ក.អ.។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៥